**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងពត៌មាន**

**MINISTRY OF INFORMATION**

លេខ ១៥៤/០៥ ព.ម ប្រក

រាជធានីភ្នំពេញ, ថ្ងៃទី ០៧ ខែ ឧសភា ឆ្នាំ ២០០៥

# ប្រកាស

## ស្តីពីការបង្កើតការិយាល័យទូរទស្សន៍ជាតិកម្ពុជា

## តាមបណ្តាខេត្ត-ក្រុង

## រដ្ឋមន្ត្រីក្រសួងពត៌មាន

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់គណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងពត៌មាន
- បានឃើញអនុក្រឹត្យលេខ ២០អនក្រ ចុះថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ១៩៩៦ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួង និង រដ្ឋលេខាធិការដ្ឋាន
- បានឃើញអនុក្រឹត្យលេខ ៧០អនក្រ.បក ចុះថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងពត៌មាន
- បានឃើញប្រកាសលេខ ០១៧.០៣ ព.ម.ប្រ.ក ចុះថ្ងៃទី ២៣ ខែ មេសា ឆ្នាំ ២០០៣ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់អគ្គនាយកដ្ឋានទូរទស្សន៍ជាតិកម្ពុជា
- យោងតាមសំណើរបស់អគ្គនាយកដ្ឋានទូរទស្សន៍ជាតិកម្ពុជា

## សំរេច

## ជំពូកទី១

**ប្រការ១.** គោលបំណង នៃការបង្កើតការិយាល័យទូរទស្សន៍ជាតិកម្ពុជាតាមបណ្តាខេត្ត-ក្រុង គឺ ៖

-ផ្តល់អោយជាអតិបរមា នូវផលចំណេញដោយសមហេតុសមផលជូនដល់ប្រជាជនគ្រប់រូប

-ធានាការអនុវត្តន៍នូវសេរីភាព នៃការបញ្ចេញយោបល់តាមរយៈការផ្សព្វផ្សាយដោយធានាអោយបាននូវភាពមិនលំអៀង ភាពត្រឹមត្រូវ និងស្វ័យភាពរបស់ការផ្សាយ

-ធ្វើអោយការផ្សាយ បានរួមវិភាគទានដល់ការអភិវឌ្ឍន៍នូវលទ្ធិប្រជាធិបតេយ្យដ៏ល្អប្រសើរ ដោយបែងចែកអោយច្បាស់នូវការទទួលខុសត្រូវរបស់បុគ្គលទាំងអស់ដែលបំពេញការងារនៅក្នុងវិស័យផ្សព្វផ្សាយ ។

**ប្រការ២.**

**ត្រូវបានបង្កើតការិយាល័យទូរទស្សន៍ជាតិកម្ពុជា តាមបណ្តាខេត្ត-ក្រុងដូចខាងក្រោម ៖**

១.ការិយាល័យទូរទស្សន៍ជាតិកម្ពុជា ក្រុងព្រះសីហនុ

២.ការិយាល័យទូរទស្សន៍ជាតិកម្ពុជា ខេត្តបាត់ដំបង

៣.ការិយាល័យទូរទស្សន៍ជាតិកម្ពុជា ខេត្តសៀមរាប

៤.ការិយាល័យទូរទស្សន៍ជាតិកម្ពុជា ខេត្តពោធិ៍សាត់

៥.ការិយាល័យទូរទស្សន៍ជាតិកម្ពុជា ខេត្តកោះកុង

៦.ការិយាល័យទូរទស្សន៍ជាតិកម្ពុជា ខេត្តរតនៈគិរី

៧.ការិយាល័យទូរទស្សន៍ជាតិកម្ពុជា ខេត្តមណ្ឌលគិរី

**ប្រការ៣.**

ការិយាល័យទូរទស្សន៍ជាតិកម្ពុជាតាមបណ្តាខេត្ត-ក្រុង ដូចមានចែងក្នុងប្រការ២ ត្រូវស្ថិតនៅក្រោមចំណុះមន្ទីរនៃអគ្គនាយកដ្ឋានទូរទស្សន៍ជាតិកម្ពុជា ។

**ប្រការ៤.**

**ការិយាល័យទូរទស្សន៍ជាតិកម្ពុជាតាមបណ្តាខេត្ត-ក្រុងមានភារកិច្ច ៖**

-ផ្សព្វផ្សាយបន្តទាំងស្រុងពីអគ្គនាយកដ្ឋានទូរទស្សន៍ជាតិកម្ពុជា

-អនុវត្តការសំរេចចិត្តពីអគ្គនាយកដ្ឋានទូរទស្សន៍ជាតិកម្ពុជា សំរាប់ការផ្សាយកម្មវិធីមូលដ្ឋាន

-អនុវត្តការសំរេចចិត្តពីអគ្គនាយកដ្ឋានទូរទស្សន៍ជាតិកម្ពុជានូវការងារបុគ្គលិក-គណនេយ្យ ផែនការ ហិរញ្ញវត្ថុ បច្ចេកទេស និង ការងារធុរៈកិច្ច

-អាចសហការជាមួយមន្ទីរពត៌មានខេត្ត-ក្រុង និងសហការជាមួយឯកជន **NGOs-OI** ដើម្បីផលិតកម្មវិធីសមស្រប ។

ការិយាល័យទូរទស្សន៍ជាតិកម្ពុជាតាមបណ្តាខេត្ត-ក្រុង ដឹកនាំដោយនាយការិយាល័យមួយរូប មានឋានៈតំណែងជាប្រធានការិយាល័យ (រដ្ឋបាលកណ្តាល) អមដោយនាយរងការិយាល័យមួយចំនួនតាមការចាំបាច់ និងមានឋានៈតំណែងជាអនុប្រធានការិយាល័យ (រដ្ឋបាលកណ្តាល) ។

## **ជំពូកទី២**

**ប្រការ៥.**

**ត្រូវបានបង្កើតការិយាល័យនានាក់ចំណុះទូរទស្សន៍ជាតិកម្ពុជាតាមបណ្តាខេត្ត-ក្រុង ក្រោមចំណុះមន្ទីរ និងនាយកដ្ឋាននានា ដូចខាងក្រោម ៖**

**ក.មន្ទីរ**

១.ការិយាល័យចាត់ចែងទូរទស្សន៍ជាតិកម្ពុជាខេត្ត-ក្រុង

**ខ.នាយកដ្ឋានពត៌មានទូរទស្សន៍ក្នុង និងក្រៅប្រទេស**

១.ការិយាល័យទំនាក់ទំនងការងារពត៌មានទូរទស្សន៍ក្នុង និងក្រៅប្រទេសជាមួយទូរទស្សន៍ជាតិកម្ពុជាខេត្ត-ក្រុង

**គ.នាយកដ្ឋានផលិតកម្មវិធីទូរទស្សន៍**

១.ការិយាល័យទំនាក់ទំនងការងារផលិតកម្មវិធីជាមួយទូរទស្សន៍ជាតិកម្ពុជាខេត្ត-ក្រុង

**ឃ.នាយកដ្ឋានបច្ចេកទេសទូរទស្សន៍ជាតិកម្ពុជា**

១.ការិយាល័យទំនាក់ទំនងការងារបច្ចេកទេសជាមួយទូរទស្សន៍ជាតិកម្ពុជាខេត្ត-ក្រុង

**ប្រការ៦.**

**ការិយាល័យចាត់ចែងទូរទស្សន៍ជាតិកម្ពុជាខេត្ត-ក្រុងមានភារកិច្ច ÷**

-គ្រោងចំណូល និងចំណាយប្រចាំឆ្នាំសំរាប់ទូរទស្សន៍ជាតិកម្ពុជាតាមបណ្តាខេត្ត-ក្រុង

-គ្រប់គ្រងអចលនទ្រព្យ ចលនទ្រព្យ និងធ្វើបញ្ជីសារពើភ័ណ្ឌ ការិយាល័យទូរទស្សន៍ជាតិកម្ពុជាតាមបណ្តាខេត្ត-ក្រុង

-ធ្វើផែនការបណ្តុះបណ្តាលជំនាញទូរទស្សន៍ និងការបំពាក់សំភារៈបច្ចេកទេសទូរទស្សន៍ព្រមទាំងការជួសជុល

-ទំនាក់ទំនងសាធារណៈទីផ្សារ វិស័យឯកជន អង្គការក្រៅរដ្ឋាភិបាល អង្គការអន្តរជាតិ ។

ការិយាល័យចាត់ចែងទូរទស្សន៍ជាតិកម្ពុជាតាមបណ្តាខេត្ត-ក្រុង ដឹកនាំដោយនាយការិយាល័យមួយរូប មានមុខតំណែងជាប្រធានការិយាល័យ( រដ្ឋបាលកណ្តាល) អមដោយនាយរងការិយាល័យមួយចំនួនតាមការចាំបាច់ និងមានមុខតំណែងជាអនុប្រធានការិយាល័យ ( រដ្ឋបាលកណ្តាល ) ។

**ប្រការ៧.**

**ការិយាល័យទំនាក់ទំនងការងារពត៌មានទូរទស្សន៍ក្នុង និងក្រៅប្រទេសជាមួយទូរទស្សន៍ជាតិកម្ពុជាខេត្ត-ក្រុង មានភារកិច្ច ÷**

តាមរយៈការិយាល័យចាត់ចែងទូរទស្សន៍ជាតិកម្ពុជាសហការជាមួយ ÷

-ផ្តត់ផ្គង់ពត៌មានគ្រប់វិស័យតាមមូលដ្ឋាន តាមរយៈកាសែត ( Tape )

-បញ្ជូនពត៌មានដោយផ្ទាល់គ្រប់វិស័យតាមរយៈការផ្សាយផ្ទាល់ ( តាមទូរស័ព្ទ ឬតាមឧបករណ៍ផ្សាយផ្ទាល់ )

-ជំរុញ និងលើកកំពស់ការងារជាមួយសហសេវិកតាមមូលដ្ឋាន ។

ការិយាល័យទំនាក់ទំនងការងារពត៌មានទូរទស្សន៍ក្នុង និងក្រៅប្រទេសជាមួយទូរទស្សន៍ជាតិកម្ពុជាខេត្ត-ក្រុង ដឹកនាំដោយនាយការិយាល័យមួយរូប មានមុខតំណែងជាប្រធានការិ យាល័យ ( រដ្ឋបាលកណ្តាល ) អមដោយនាយរងការិយាល័យមួយចំនួនតាមការចាំបាច់ និងមានមុខតំណែងជាអនុប្រធានការិយាល័យ ( រដ្ឋបាលកណ្តាល ) ។

**ប្រការ៨.**

**ការិយាល័យទំនាក់ទំនងការងារផលិតកម្មវិធីទូរទស្សន៍ជាតិកម្ពុជាខេត្ត-ក្រុងមានភារកិច្ច ÷**

តាមរយៈការិយាល័យចាត់ចែងទូរទស្សន៍ជាតិកម្ពុជាខេត្ត-ក្រុង សហការជាមួយ ÷

-ផ្គត់ផ្គង់កម្មវិធីកំសាន្ត អប់រំ ឯកសារ កុមារ.... ។ល។

-ផ្តល់តារាងរៀបចំកម្មវិធីប្រចាំសប្តាហ៍

-ស្រាវជ្រាវទស្សនៈទស្សនិកជនរបស់មូលដ្ឋាន និងសិទ្ធិផ្សព្វផ្សាយ ។

ការិយាល័យទំនាក់ទំនងការងារផលិតកម្មវិធីទូរទស្សន៍ជាតិកម្ពុជាខេត្ត-ក្រុង ដឹកនាំដោយនាយការិយាល័យមួយរូប មានមុខតំណែងជាប្រធានការិយាល័យ (រដ្ឋបាលកណ្តាល) អមដោយនាយរងការិយាល័យមួយចំនួនតាមការចាំបាច់ និងមានមុខតំណែងជាអនុប្រធានការិយាល័យ (រដ្ឋបាលកណ្តាល) ។

**ប្រការ៩.**

**ការិយាល័យទំនាក់ទំនងការងារបច្ចេកទេសជាមួយទូរទស្សន៍ជាតិកម្ពុជាខេត្ត-ក្រុងមានភារកិច្ច ÷**

តាមរយៈការិយាល័យចាត់ចែងទូរទស្សន៍ជាតិកម្ពុជាខេត្ត-ក្រុង សហការជាមួយ ÷

-ធ្វើផែនការថែទាំ និង ជួសជុលសំភារៈបច្ចេកទេស

-ត្រួតពិនិត្យស្ថានភាពប្រតិបត្តិការ និងបច្ចេកទេសផលិត និងផ្សាយ

-ធ្វើផែនការអភិវឌ្ឍន៍វិស័យបច្ចេកវិទ្យាពត៌មាន (ICT)

ការិយាល័យទំនាក់ទំនងការងារបច្ចេកទេសជាមួយទូរទស្សន៍ជាតិកម្ពុជាខេត្ត-ក្រុង ដឹកនាំដោយនាយការិយាល័យមួយរូប មានមុខតំណែងជាប្រធានការិយាល័យ (រដ្ឋបាលកណ្តាល) អមដោយនាយរងការិយាល័យមួយចំនួនតាមការចាំបាច់ និងមានមុខតំណែងជាអនុប្រធានការិយាល័យ (រដ្ឋបាលកណ្តាល) ។

**ប្រការ១០.**

ឧបសម្ព័ន្ធនៃប្រកាសលេខ ០១៧.០៣ ព.ម.ប្រ.ក ចុះថ្ងៃទី ២៣ ខែ មករា ឆ្នាំ ២០០៣ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គនាយកដ្ឋានទូរទស្សន៍ជាតិកម្ពុជា ត្រូវទុកជានិរាករណ៍ ។

**ប្រការ១១.**

អង្គការលេខរបស់អគ្គនាយកដ្ឋានទូរទស្សន៍ជាតិកម្ពុជា (TVK) ជាឧបសម្ព័ន្ធនៃប្រកាសនេះ ។

**ប្រការ១២.**

អគ្គនាយកដ្ឋានទូរទស្សន៍ជាតិកម្ពុជា ( TVK ) គ្រប់អគ្គនាយកដ្ឋានចំណុះក្រសួងពត៌មាន និងអង្គភាពពាក់ព័ន្ធត្រូវអនុវត្ត ប្រកាសនេះតាមភារកិច្ចរៀង១ខ្លួន អោយមានប្រសិទ្ធិភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋមន្ត្រី

ខៀវ កាញារីទ្ធ

**<u>ចំលងជូន</u>**

-ទីស្តីការគណៈរដ្ឋមន្ត្រី

-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ

-រាជកិច្ច

-ឯកសារ

ឧបសម្ព័ន្ធនៃប្រកាសលេខ..១២៤/..០៥..ព.មប្រកចុះថ្ងៃទី.០៦..ខែ.ឧសភា.ឆ្នាំ ២០០៥

អង្គការលេខនៃអគ្គនាយកដ្ឋានទូរទស្សន៍ជាតិកម្ពុជា

